# គោលនយោបាយសិទ្ធិមនុស្ស NIPPN Group

<បុព្វកថា>

ដោយផ្អែកលើទស្សនវិស័យគ្រប់គ្រង នៅគ្រប់សកម្មភាពសហគ្រាសទាំងមូល NIPPN Group នឹងបំពេញទំនួលខុសត្រូវគោរពសិទ្ធិមនុស្សដែលផ្អែកលើសេចក្តីថ្លៃថ្នូររបស់មនុស្សដែលមិនអាចខ្វះបានសម្រាប់មនុស្សគ្រប់រូបដើម្បីធានាឲ្យបានការរស់នៅនិងសេរីភាពដែលមានពីកំណើត និងដើម្បីរស់នៅជីវិតប្រកបដោយសុភមង្គលក្នុងសង្គម។ គោលនយោបាយនេះត្រូវបានចាត់ថ្នាក់ជាគោលនយោបាយកម្រិតកំពូលទាក់ទងនឹងសិទ្ធិមនុស្សនៅក្នុង NIPPN Group។

<តួសេចក្តី>

1. គំនិតជាមូលដ្ឋាន

NIPPN Group គាំទ្រនិងគោរពនិយាមនៃសិទ្ធិមនុស្សជាអន្តរជាតិដូចជា "កម្រងច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស" (សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស) និង "សេចក្តីប្រកាសរបស់ ILO ស្តីពីគោលការណ៍ជាមូលដ្ឋាននិងសិទ្ធិនៅក្នុងការងារ" របស់អង្គការពលកម្មអន្តរជាតិ (ILO)។ ម្យ៉ាងទៀត យើងខិតខំប្រឹងប្រែងក្នុងការគោរពសិទ្ធិមនុស្ស ស្របតាម "គោលការណ៍ណែនាំទាក់ទងនឹងធុរកិច្ចនិងសិទ្ធិមនុស្ស" របស់អង្គការសហប្រជាជាតិ។ NIPPN Group គោរពតាមច្បាប់និងបទប្បញ្ញត្តិនៃប្រទេសនិងតំបន់នីមួយៗដែលខ្លួនធ្វើសកម្មភាពអាជីវកម្ម។ ក្នុងករណីដែលនិយាមនៃសិទ្ធិមនុស្សជាអន្តរជាតិខុសពីច្បាប់និងបទប្បញ្ញត្តិរបស់ប្រទេស/តំបន់នីមួយៗ យើងនឹងគោរពតាមស្តង់ដារដែលខ្ពស់ជាង ហើយក្នុងករណីដែលមិនស៊ីសង្វាក់គ្នា យើងស្វែងរកវិធីដើម្បីគោរពសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិក្នុងកម្រិតអតិបរមាដែលអាចធ្វើទៅបាន។

2. វិសាលភាពនៃការអនុវត្ត

គោលនយោបាយនេះគឺអនុវត្តចំពោះនាយកនិងបុគ្គលិកជាដើមទាំងអស់របស់ NIPPN Group។ ម្យ៉ាងទៀត យើងលើកទឹកចិត្តដៃគូអាជីវកម្មរបស់ NIPPN Group ទាំងអស់នៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ ឱ្យគាំទ្រគោលនយោបាយនេះ និងខិតខំគោរពសិទ្ធិមនុស្ស ហើយធ្វើការរួមគ្នាដើម្បីជំរុញការគោរពសិទ្ធិមនុស្ស។

3. ការត្រួតពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិមនុស្ស

ដើម្បីបំពេញទំនួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្ស NIPPN Group បង្កើតយន្តការត្រួតពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិមនុស្ស កំណត់អត្តសញ្ញាណនៃផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្សដែលពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មរបស់ NIPPN Group ហើយបន្តអនុវត្តកិច្ចខិតខំប្រឹងប្រែងជាប់ជាបន្តក្នុងការបង្ការនិងកាត់បន្ថយវា។

4. ការជួយសង្គ្រោះ

ប្រសិនបើ NIPPN Group បានបង្កឬរួមចំណែកបង្កផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស

យើងនឹងខិតខំប្រឹងប្រែងកែតម្រូវ/ជួយសង្គ្រោះ។ ម្យ៉ាងទៀត ក្នុងករណីដែលសកម្មភាពអាជីវកម្ម ផលិតផល ឬសេវាកម្មរបស់ NIPPN Group ពាក់ព័ន្ធដោយផ្ទាល់នឹងផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្សតាមរយៈទំនាក់ទំនងអាជីវកម្ម យើងនឹងលើកទឹកចិត្តដៃគូអាជីវកម្មរបស់យើងឲ្យបង្ការនិងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស។

5. ការអប់រំ

NIPPN Group អនុវត្តការអប់រំបណ្តុះបណ្តាលដែលសមស្របជាប់ជាបន្តដល់នាយកនិងបុគ្គលិកជាដើមទាំងអស់ដើម្បីឲ្យសកម្មភាពអាជីវកម្មដែលស្របតាមគោលនយោបាយនេះត្រូវបានអនុវត្ត។

6. ការសន្ទនា

NIPPN Group ធ្វើការសន្ទនា/ពិភាក្សាជាមួយភាគីពាក់ព័ន្ធក្នុងការជំរុញកិច្ចខិតខំប្រឹងប្រែងដើម្បីគោរពសិទ្ធិមនុស្ស។

7. ការបង្ហាញព័ត៌មាន

NIPPN Group បង្ហាញទាន់ពេលវេលានិងសមស្របអំពីកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការគោរពសិទ្ធិមនុស្សដោយផ្អែកលើគោលនយោបាយនេះ នៅលើវេបសាយជាដើម។

8. ប្រព័ន្ធ

យើងបង្កើតប្រព័ន្ធសម្រាប់អនុវត្តគោលនយោបាយនេះ។ ម្យ៉ាងទៀត ក្រុមប្រឹក្សាភិបាលនឹងឃ្លាំមើលស្ថានភាពនៃការអនុវត្ត/អនុលោមនៃគោលនយោបាយនេះ។

9. បញ្ហាប្រឈមអំពីសិទ្ធិមនុស្ស

យើងបង្ហាញគោលនយោបាយអំពីកិច្ចខិតខំប្រឹងប្រែងពាក់ព័ន្ធនឹងបញ្ហាប្រឈមអំពីសិទ្ធិមនុស្សដែល NIPPN Group អនុវត្ត នៅក្នុងឧបសម្ព័ន្ធ។ បញ្ហាប្រឈមអំពីសិទ្ធិមនុស្សដែលបង្ហាញក្នុងឧបសម្ព័ន្ធនឹងត្រូវបានពិនិត្យឡើងវិញតាមភាពចាំបាច់ដោយផ្អែកលើការប្រែប្រួលនៃសង្គមដែលរួមទាំងសកម្មភាពអាជីវកម្មរបស់ NIPPN Group និងច្បាប់និងបទប្បញ្ញត្តិជាដើម។

បង្កើតឡើងនៅថ្ងៃទី 23 ខែឧសភា ឆ្នាំ 2025

ក្រុមហ៊ុន NIPPN

ប្រធានក្រុមប្រឹក្សាភិបាល អគ្គនាយកប្រតិបត្តិ

ម៉ាអេហ្ស៊ិរុ គូស៊ីយ៉ា

ឧបសម្ព័ន្ធនៃគោលនយោបាយសិទ្ធិមនុស្ស NIPPN Group

ឧបសម្ព័ន្ធនេះបង្ហាញគោលនយោបាយអំពីកិច្ចខិតខំប្រឹងប្រែងពាក់ព័ន្ធនឹងបញ្ហាប្រឈមអំពីសិទ្ធិមនុស្សរបស់ NIPPN Group។
បញ្ហាប្រឈមអំពីសិទ្ធិមនុស្សដែលបង្ហាញក្នុងឧបសម្ព័ន្ធ
នឹងត្រូវបានពិនិត្យឡើងវិញតាមភាពចាំបាច់ដោយផ្អែកលើការប្រែប្រួលនៃសង្គមដែលរួមទាំងអាជីវកម្មរបស់ NIPPN Group និងច្បាប់និងបទប្បញ្ញត្តិជាដើម។

（1） ពលកម្មដោយបង្ខំ ពលកម្មកុមារ
យើងហាមឃាត់យ៉ាងតឹងរឹងនូវគ្រប់ទម្រង់នៃការជួញដូរមនុស្ស ពលកម្មដោយបង្ខំ
ពលកម្មបែបទាសករ និងពលកម្មកុមារ នៅក្នុងប្រទេស តំបន់
ទាំងអស់ដែលយើងអនុវត្តសកម្មភាពអាជីវកម្ម។

（2） ការរើសអើង
យើងគោរពសិទ្ធិមនុស្សជាមូលដ្ឋាន និងហាមឃាត់ការរើសអើងទាំងឡាយណាដែលផ្អែកលើ
ពូជសាសន៍ ពណ៌សម្បុរ សាសនា ទស្សនៈនយោបាយ ភេទ អត្តសញ្ញាណយេនឌ័រ ទំនោរផ្លូវភេទ
អាយុ ដើមកំណើតប្រជាជន ដើមកំណើតសង្គម ពិការភាពជាដើម។
ម្យ៉ាងទៀត យើងមិនអនុញ្ញាតដាច់ខាតនូវការបៀតបៀនគ្រប់ទម្រង់។

（3） សេរីភាពក្នុងការរួបរួមបង្កើតសមាគម និងសិទ្ធិចរចាជាសមូហភាព
យើងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិនិងការអនុវត្តពាក់ព័ន្ធនឹងការងាររបស់ប្រទេស តំបន់
ទាំងអស់ដែលយើងធ្វើសកម្មភាពអាជីវកម្ម
ហើយទន្ទឹមនឹងនេះយើងគោរពសិទ្ធិការងារជាមូលដ្ឋានដូចជាសិទ្ធិបង្កើតសហជីព
សិទ្ធិចរចាជាសមូហភាពជាដើមរបស់និយោជិត
ហើយកសាងទំនាក់ទំនងនិយោជិតនិយោជកដ៏ប្រសើរជាមួយបុគ្គលិកម្នាក់ៗ។

（4） សុវត្ថិភាពអនាម័យក្នុងការងារ
យើងបង្ការគ្រោះថ្នាក់ការងារដោយផ្អែកតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការងាររបស់ប្រទេស តំបន់ទាំងអស់ដែលយើងធ្វើសកម្មភាពអាជីវកម្ម ហើយខិតខំរៀបចំ រក្សានិងកែលម្អបរិស្ថានកន្លែងការងារដែលអាចធ្វើការងារដោយសុវត្ថិភាពនិងមានអនាម័យ។

（5） ប្រាក់ឈ្នួលសមស្រប/ម៉ោងធ្វើការត្រឹមត្រូវ
យើងបង់ប្រាក់ឈ្នួលសមស្របដែលមិនក្រោមប្រាក់ឈ្នួលអប្បបរមា
និងគ្រប់គ្រងម៉ោងធ្វើការត្រឹមត្រូវ
ដោយផ្អែកតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការងាររបស់ប្រទេស តំបន់
ទាំងអស់ដែលយើងធ្វើសកម្មភាពអាជីវកម្ម។

（6） ការគោរពភាពចម្រុះនិងការបង្កើតបរិស្ថានកន្លែងការងារដែលងាយស្រួលធ្វើការ

យើងប្រឹងប្រែងបង្កើតកន្លែងធ្វើការដែលពោរពេញដោយ DE&I (ភាពចម្រុះ សមធម៌
និងភាពរួមបញ្ចូល)
ហើយសំដៅឆ្ពោះទៅបរិស្ថានកន្លែងការងារដែលងាយស្រួលធ្វើការដែលបុគ្គលិកម្នាក់ៗអាចបញ្ចេញ
សមត្ថភាពបានខ្ពស់បំផុត
ហើយអាចទទួលបានអារម្មណ៍ខ្លួនឯងមានការរីកចម្រើននិងអារម្មណ៍បញ្ចេញសក្តានុពលខ្លួនឯង
។

（7） ការធ្វើទំនាក់ទំនងទីផ្សារដែលមានទំនួលខុសត្រូវ
យើងហាមឃាត់ការធ្វើទំនាក់ទំនងទីផ្សារដែលមានការបង្ហាញខុសពីការពិតដូចជាការបង្អួត/បំ
ផ្លើសជាដើម ការសម្តែងពាក្យពេចន៍បែបរើសអើង ឬខ្លឹមសារដែលជះឥទ្ធិពលអាក្រក់ដល់កុមារ។

（8） សុវត្ថិភាពអ្នកប្រើប្រាស់
យើងខិតខំក្នុងការគ្រប់គ្រងគុណភាព សុវត្ថិភាពនៃផលិតផល
ការបង្កើតផ្លាកបង្ហាញដែលងាយស្រួលយល់ ហើយការពារសុវត្ថិភាព/ភាពទុកចិត្តបាន
និងសុខភាពអ្នកប្រើប្រាស់។

（9） ការការពារព័ត៌មានបុគ្គល
យើងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិទាក់ទងនឹងការការពារព័ត៌មាន
និងច្បាប់បទប្បញ្ញត្តិពាក់ព័ន្ធ
ដោយផ្អែកតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការងាររបស់ប្រទេស តំបន់
ទាំងអស់ដែលយើងធ្វើសកម្មភាពអាជីវកម្ម
ហើយខិតខំក្នុងការចាត់ចែងត្រឹមត្រូវនូវព័ត៌មានបុគ្គល។

（10） សុខដុមជាមួយភាគីពាក់ព័ន្ធផ្សេងៗ
យើងគោរពសិទ្ធិមនុស្សរបស់ភាគីពាក់ព័ន្ធទាំងអស់ដែលពាក់ព័ន្ធនៅក្នុងច្រវាក់ផ្គត់ផ្គង់ទាំងមូល។
ម្យ៉ាងទៀត យើងសំដៅសុខដុមជាមួយសហគមន៍មូលដ្ឋានដែលយើងធ្វើសកម្មភាពអាជីវកម្ម
ហើយខិតខំប្រឹងប្រែងក្នុងការឆ្លើយតបចាំបាច់ដើម្បីបង្ការឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទៅ
លើសុខភាព សិទ្ធិលើដីធ្លី ការប្រើប្រាស់ទឹកជាដើម
របស់ប្រជាជនក្នុងតំបន់ដែលយើងធ្វើសកម្មភាពអាជីវកម្ម។

បង្កើតឡើងនៅថ្ងៃទី 23 ខែឧសភា ឆ្នាំ 2025